ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
ចូល
លេខ ១៦២
ថ្ងៃទី ១ ខែ ៣ ឆ្នាំ២០២៤
ម៉ោង ១០:៣០
បញ្ជូន ១០ : ២០

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**
លេខៈ ៣១៦ ស.ស.ណ.អ.ស

ថ្ងៃ សុក្រ ១០ រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មីនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**កម្មវត្ថុ៖** ករណីរបាយការណ៍ស្តីពីលទ្ធផលនៃការចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីឌីជីថលអាស៊ានលើកទី៤ និងកិច្ចប្រជុំពាក់ព័ន្ធ ជាមួយដៃគូសន្ទនានៅប្រទេសសិង្ហបុរី ចាប់ពីថ្ងៃទី១-២ ខែកុម្ភៈ ឆ្នាំ២០២៤ និងសំណើគោរពសុំគោលការណ៍លើការងារបន្ត។

**យោង** ៖- លិខិតលេខ៣៥១ បទ. ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូន ឯកឧត្តមរដ្ឋមន្ត្រី ជ្រាបថា រាជរដ្ឋាភិបាលសូមអបអរសាទរ ចំពោះជោគជ័យទទួលបានមេដាយមាស នៃកម្មវិធី “ថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh” និងឯកភាពលើសំណើសម្រាប់ការងារបន្ត ដូចខាងក្រោម៖

១. បង្កើតក្រុមការងារបច្ចេកទេស ដើម្បីពិនិត្យ តាមដាន និងស្រាវជ្រាវលើបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត និងជាតំណាងកម្ពុជា ក្នុងការបំពេញការងារពាក់ព័ន្ធនឹងបញ្ញាសិប្បនិម្មិតក្នុងក្របខ័ណ្ឌនៃរដ្ឋមន្ត្រីឌីជីថលអាស៊ាន។

២. សហការជាមួយប្រទេសជាសមាជិកអាស៊ាន ឬប្រទេសដៃគូផ្សេងទៀត ដែលមានចំណាប់អារម្មណ៍ប្រើប្រាស់ “ថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh” នៅក្នុងប្រទេសរបស់ខ្លួន និងអាចឈានទៅដល់ការប្រើប្រាស់ជាប្រព័ន្ធរួមនៅក្នុងតំបន់អាស៊ានទាំងមូល។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តមរដ្ឋមន្ត្រី ជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ហ៊ុយ វណ្ណៈ**

**ចម្លងជូន៖**
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ឯកសារ កាលប្បវត្តិ